## ព័ត៌មានទូទៅអំពីមូលនិធិ ស.អ. ឬ CBR&D

មូលនិធិ **ស.អ.** ដែលមានឈ្មោះពេញថា មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គឺជាមូលនិធិ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីទ្រទ្រង់ និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍវិស័យ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការទ្រទ្រង់វិស័យទាំងមូល ក៏ដូចជាដើម្បីការកសាងឧស្សាហកម្មនេះនៅកម្ពុជាប្រកបដោយភាពប្រកួតប្រជែងក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល។

មូលនិធិ **ស.អ.** នេះ ស្ថិតនៅក្រោមការគ្រប់គ្រង ការចាត់ចែង និងការទទួលខុសត្រូវរបស់ **ក្រុមប្រឹក្សាភិបាលមូលនិធិ ស.អ.** ដែលត្រូវបានតែងតាំងដោយសេចក្តីសម្រេចលេខ២៦៨ សសរ. ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ ស្តីពី "ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលមូលនិធិ នៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន" ។